CITY OF LONG BEACH

# សេចក្តីប្រកាសពត៌មាន

សាលាក្រុងឡុងប៊ីឆ
ការិយាល័យពត៌មានសាធារណៈ
411 W. Ocean Blvd,
Long Beach, CA 90802

---

**4/2/2020**

សំរាប់ផ្សព្វផ្សាយបន្ទាន់ សេចក្តីប្រកាសពត៌មាន# 032820B

**ប្រធានបទ:** **ពត៌មានថ្មីបំផុត: ទីជំរកបណ្តោះអាសន្ន បើកនៅឯសួនច្បារ Silverado Park**
ទីជំរកបណ្តោះអាសន្នបន្ថែមផ្សេងៗទៀត និងត្រូវបង្កើតឡើង

**ទំនាក់ទំនង:** មជ្ឍមណ្ឌលពត៌មានរួម សាលាក្រុងឡុងប៊ីឆ
562.570.NEWS
jic@longbeach.gov

ក្រុងឡុងប៊ីឆ, រដ្ឋកាលីហ្វ័រញ៉ា - សាលាក្រុងឡុងប៊ីឆ បានបើកទីជំរកហៅស៊ីងបណ្តោះអាសន្នមួយ នៅឯសួនច្បារ Silverado Park, ដែលមានទីតាំងស្ថិតនៅផ្ទះលេខ1545 W. 31st St., ដើម្បីផ្តល់នូវហៅស៊ីងបន្ថែម, បណ្តោះអាសន្ន ទៅកាន់មនុស្សទាំងឡាយ ដែលកំពុងជួបប្រទះនូវភាពអត់មានផ្ទះសំបែងក្នុងស៊ីធី ក្នុងអំឡុងពេលនៃការរាតត្បាតនៃជំងឺ COVID-19 ដែលកំពុងមានជាបន្តរនេះ។

អភិបាលក្រុង Robert Garcia មានប្រសាសន៍ថា "យើងមានការប្តេជ្ញាចិត្ត ក្នុងការផ្តល់នូវទីជំរកទៅកាន់សមាជិកនានា ដែលជាជនងាយរងគ្រោះបំផុត នៃសហគមន៍របស់ពួកយើង នៅក្នុងន័យដែលអនុញ្ញាតិអោយពួកគេឆ្ងាយពីសង្គម ជាពិសេសក្នុងអំឡុងពេល មានវិបត្តិសុខភាពសាធារណៈនេះ,"។ "ខ្ញុំមានមោទនៈភាពណាស់ចំពោះក្រុមស៊ីធីរបស់ពួកយើង ដែលធ្វើការទាំងយប់ទាំងថ្ងៃ ក្នុងការផ្តល់នូវជំនួយដែលមានតំរូវការបំផុត ទៅកាន់អ្នកដែលត្រូវការ, និងចៅសង្កាត់របស់ពួកយើង ក្នុងការគាំទ្រនូវការងារដ៏មានសារៈសំខាន់នេះ"។

ទីជំរកសួនច្បារ Silverado Park គឺជាទីជំរកដំបូង នៃជំរកបណ្តោះអាសន្នមួយចំនួន ដែលបានត្រូវបង្កើតឡើង ដើម្បីបំរើប្រជាជនដែលងាយរងគ្រោះទាំងឡាយ ដើម្បីដោះស្រាយនូវឥទ្ធិពលនៃជំងឺ COVID-19 កំពុងតែមាននេះ។ ទីជំរក 24-7 និងផ្តល់ជំរកដល់មនុស្សប្រហែល 50 នាក់ នៅក្នុងបន្ទប់ធំ ជាមួយនិងការនៅឆ្ងាយសង្គម រវាងគ្រែមួយទៅគ្រែមួយ និងមនុស្ស ៧ នាក់បន្ថែម ក្នុងបន្ទប់ចែកដាច់ដោយឡែកមួយទៀតនិងត្រូវប្រើប្រាស់ ពេលមានតំរូវការ។

មានការផ្តល់នូវការសំរាំងសុខភាពដែលត្រូវតែធ្វើ តំរូវដោយច្បាប់ទៅកាន់មនុស្សទាំងអស់ មុនពេលចូលទៅកាន់ទីជំរក ហើយនិងធ្វើការលើកទឹកចិត្តមនុស្សទាំងឡាយ អោយអនុវត្តតាមម៉ូដែល ដែលដាក់អោយធ្វើនៅក្នុងទីជំរក ដើម្បីបង្កើននូវសុវត្ថិភាព ដល់អ្នករស់នៅទាំងអស់ក្នុងទីជំរក។ **ពត៌មានថ្មីបំផុត: 4/01/20:** ដើម្បីទទួលសេវានានា បុគ្គលម្នាក់ៗ ត្រូវតែទស្សនាមណ្ឌលសេវាកម្មចំរុះ (Multi-Service Center) ដែលមានទីតាំងនៅ1301 W. 12th Street, ដើម្បីបំពេញ

នូវការប៉ាន់ប្រមាណទីជំរក និងការសំរាំងសុខភាព។ បន្ទាប់ពីបញ្ចប់ការធ្វើសំរាំងសុខភាព បុគ្គលម្នាក់ៗនិងត្រូវដឹកតាមឡានក្រុង ទៅកាន់ទីតាំងជំរក។

ទីជំរកសួនច្បារ Silverado Park និងផ្តល់ការប៉ាន់ប្រមាណចំណាត់ថ្នាក់ក្រុមនានា, អាហារ, អាហារសំរន់, ការកំសាន្តសប្បាយ ដោយការគិតដល់ការអោយនៅឆ្ងាយពីសង្គម និងធនធានសេវាសង្គមនានាបន្ថែមទៀត ទៅតាមតំរូវការ។

មូលនិធិសំរាប់ទីជំរកនេះ ផ្តល់ដោយជំនួយសង្រ្គោះបន្ទាន់របស់រដ្ឋកាលីហ្វ័រញ៉ា ទៅកាន់រដ្ឋាភិបាលថ្នាក់មូលដ្ឋាន ដែលបានចែកអោយ ដោយអភិបាលរដ្ឋ Newsom ជាពិសេស ដើម្បីការពារប្រជាជនកាលីហ្វ័រញ៉ា ដែលកំពុងជួបប្រទះភាពអត់មានផ្ទះសំបែង។ ទីជំរកសួនច្បារ Silverado Park ចាត់ចែងដោយបុគ្គលិកស៊ីធី អ្នកស្ម័គ្រចិត្ត និងបុគ្គលិកអង្គការក្រៅរដ្ឋាភិបាលនានា។ ផែនការស៊ីធី គឺធ្វើជាដៃគូរជាមួយនិងទីភ្នាក់ងារផ្តល់ទីជំរកដ៏ទៃផ្សេងៗ សំរាប់ទីតាំងជំរកនានានៅពេលអនាគត។

ផងដែរ ទីតាំងផ្សេងៗទៀត រួមមានម៉ូតែល និងកន្លែងសាធារណៈនានានៅក្នុងស៊ីធីបាននឹងកំពុងស្វះស្វែងរក ដើម្បីដាក់បំរើជាទីតាំងជំរកបណ្តោះអាសន្ននាពេលអនាគត ក្នុងកិច្ចប្រឹងប្រែងយ៉ាងទូលំទូលាយក្នុងការផ្តល់នូវទីជំរក ទៅកាន់អ្នកដែលមានតំរូវការទាំងនោះ តាមតែអាចធ្វើទៅបាន។

លើសពីនេះទៀត ទីជំរកសិសិររដូវ ដែលពីដើមឡើយបានកំណត់ពេលអោយបិទនៅថ្ងៃទី៣០ ខែមិនា បានពន្យាពេលប្រតិបត្តិការរបស់ខ្លួន ទៅដល់ថ្ងៃទី៣០ ខែកញ្ញា។ នៅថ្ងៃទី១ ខែមេសា ឆ្នាំ២០២០ ទីជំរកសិសិររដូវ និងត្រូវប្តូរទីតាំង ពីទីកន្លែងបច្ចុប្បន្ន ដែលស្ថិតនៅអាស័យដ្ឋាន 1718 និង 1722 Hayes Ave. ទៅកាន់ទីកន្លែងដែលធំជាងមុន នៅឯបណ្ណាល័យចាស់ ក្រុងឡុងប៊ីឆខាងជើង ដែលស្ថិតនៅ 5571 Orange Ave., ដើម្បីអនុលោមទៅតាមការនៅឆ្ងាយសង្គម។ ទីតាំងថ្មី និងផ្តល់ទីជំរកដល់មនុស្ស ៨០ នាក់បន្ថែមទៀត ដែលពុំដូច្នោះទេ អ្នកទាំងនោះនិងមិនមានកន្លែងស្នាក់នៅឡើយក្នុងកំឡុងពេលនេះ។ នៅពេលដែលទីជំរកសិសិររដូវ បានធ្វើការផ្លាស់ប្តូរទីតាំងទាំងស្រុងទៅកាន់ទីកន្លែងថ្មីហើយនោះ ទីកន្លែងដែលមានស្រាប់នេះ និងផ្លាស់ប្តូរទៅជាកន្លែងជំរកបណ្តោះអាសន្នមួយទៀត ដែលប្រតិបត្តិការដោយសាលាក្រុងឡុងប៊ីឆ ហើយនិងផ្តល់ទីជំរកដល់មនុស្សប្រហែលពី៦០ ទៅ៧០ នាក់ បន្ថែមទៀត។

សំរាប់ពត៌មានបន្ថែម ស្តីអំពីការប្រតិបត្តិទីជំរក, ទូរស័ព្ទទៅលេខ (562) 570-9328.

សំរាប់ពត៌មានថ្មីៗបំផុតស្តីអំពីជំងឺ COVID-19, ជាមួយនិងពត៌មានពិស្តារទាំងឡាយ ដែលសាលាក្រុងឡុងប៊ីឆកំពុងតែធ្វើ ដើម្បីរក្សានូវប្រជាពលរដ្ឋទាំងអស់របស់ខ្លួន អោយមានសុវត្ថិភាព, ទស្សនា www.longbeach.gov/COVID19 និងតាមមើល @LongBeachCity លើ Facebook, Twitter និង Instagram.

សំរាប់ពត៌មាន, រូបភាព, វីឌីអូ និងសេចក្តីប្រកាសនានាបន្ថែមទៀត នៃអ្វីដែលកំពុងកើតឡើងក្នុងក្រុងឡុងប៊ីឆ តាមមើលពួកយើង លើ Facebook, Twitter, Instagram និង YouTube.